**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...៣២៣...សហវ...ប្រក

# ប្រកាស

## ស្តីពី

## ការផ្តល់អាជ្ញាបណ្ណអាជីវកម្មឆានារ៉ាប់រងបន្ត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១ ស្តីពីការធានារ៉ាប់រង
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.

ទូរសព្ទ : ៨៥៥-២៣-៤៣០ ២២៥ ទូរសារ : ៨៥៥-២៣-៤៣០ ៧៩៩
Phone : 855-23-430 225 / Fax : 855-23-430 799

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.**_

ប្រកាសនេះមានគោលបំណង÷

- ផ្តល់នីតិភាពដល់នីតិបុគ្គលក្នុងការធ្វើអាជីវកម្មធានារ៉ាប់រងបន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រង និងត្រួតពិនិត្យដំណើរការអាជីវកម្មធានារ៉ាប់រងធានារ៉ាប់រងបន្តនៅក្នុងព្រះរាជាណាចក្រ-កម្ពុជា ស្របតាមច្បាប់ស្តីពីការធានារ៉ាប់រង និងបទប្បញ្ញត្តិពាក់ព័ន្ធ
- ការពារផលប្រយោជន៍សាធារណជនលើវិស័យធានារ៉ាប់រង
- ជំរុញឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាពនៃទីផ្សារធានារ៉ាប់រង។

**ប្រការ ២.**_

ប្រកាសនេះមានគោលដៅបង្កើតក្របខណ្ឌបទប្បញ្ញត្តិ និង នីតិវិធីក្នុងការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងបន្ត ជូនក្រុមហ៊ុនធានារ៉ាប់រងបន្ត ស្របតាមច្បាប់ស្តីពីការធានារ៉ាប់រង និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**ប្រការ ៣.**_

វិសាលភាពអនុវត្តចំពោះគ្រប់អាជីវកម្មធានារ៉ាប់រងបន្តទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាលើកលែងតែ អាជីវកម្មធានារ៉ាប់រងបន្តរបស់ក្រុមហ៊ុន កម្ពុជា រី។

**ប្រការ ៤.**_

វាក្យស័ព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះ មាននិយមន័យដូចតទៅ÷

- **ក្រសួង** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- **ក្រុមហ៊ុនធានារ៉ាប់រងបន្ត** សំដៅដល់ក្រុមហ៊ុនដែលមានសិទ្ធិធ្វើអាជីវកម្មធានារ៉ាប់រងបន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនធានារ៉ាប់រងបន្ត មានសិទ្ធិចុះកិច្ចព្រមព្រៀងបន្តចូលជាមួយក្រុមហ៊ុនធានារ៉ាប់រង ឬក្រុមហ៊ុនធានារ៉ាប់រងបន្តដើម្បីទទួលហានិភ័យមួយផ្នែក ឬទាំងស្រុងពីក្រុមហ៊ុនធានារ៉ាប់រង ឬក្រុមហ៊ុនធានារ៉ាប់រងបន្ត។ ក្រុមហ៊ុនធានារ៉ាប់រងបន្តមានសិទ្ធិចុះកិច្ចព្រម

ព្រៀងបន្តចេញ តែជាមួយក្រុមហ៊ុនធានារ៉ាប់រងបន្តប៉ុណ្ណោះ ដើម្បីផ្ទេរហានិភ័យមួយផ្នែក ឬទាំងស្រុងពីក្រុមហ៊ុនធានារ៉ាប់រង ឬក្រុមហ៊ុនធានារ៉ាប់រងបន្ត។

- **ពាក្យស្នើសុំអាជ្ញាបណ្ណ** សំដៅដល់ពាក្យស្នើសុំអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងបន្តដែលត្រូវបានផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី ២

## ការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងបន្ត

### ប្រការ ៥._

មានតែនីតិបុគ្គលប្រតិស្រុតទើបអាចធ្វើអាជីវកម្មធានារ៉ាប់រងបន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន។ ក្រុមហ៊ុនធានារ៉ាប់រងបន្តទាំងអស់ ទោះបីជារបស់រដ្ឋក្តី ជារបស់ឯកជនក្តី ឬជាក្រុមហ៊ុនចម្រុះក្តីអាចត្រូវអនុញ្ញាតឱ្យធ្វើប្រតិបត្តិការធានារ៉ាប់រងបន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា តែក្នុងទ្រង់ទ្រាយជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតប៉ុណ្ណោះ។ ក្រុមហ៊ុនធានារ៉ាប់រងបន្តដែលមានភាគទុនិកជារូបវន្តបុគ្គលទាំងអស់ត្រូវមានសមាសភាពភាគទុនិកយ៉ាងតិច ៣រូប ។

### ប្រការ ៦._

បុគ្គលដែលមានបំណងប្រកបអាជីវកម្មធានារ៉ាប់រងបន្តជាក្រុមហ៊ុនបង្កើតថ្មីនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងបន្តមកក្រសួង។ មុននឹងដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ បុគ្គលត្រូវស្នើសុំគោលការណ៍អនុញ្ញាតពីលទ្ធភាពទទួលបានអាជ្ញាបណ្ណ ដែលឯកសារតម្រូវលម្អិតសម្រាប់ការស្នើសុំគោលការណ៍អនុញ្ញាតក្នុងដំណាក់កាលដំបូងមានដូចខាងក្រោម÷

- លិខិតស្នើសុំគោលការណ៍អនុញ្ញាតប្រកបអាជីវកម្មធានារ៉ាប់រងបន្ត
- ឯកសារសិក្សាសមិទ្ធិលទ្ធភាពនៃទីផ្សារធានារ៉ាប់រងបន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ផែនការអាជីវកម្មរយៈពេល ៥ ឆ្នាំ រួមមាន÷ តារាងតុល្យការ របាយការណ៍លំហូរសាច់ប្រាក់ របាយការណ៍លទ្ធផល និងរបាយការណ៍បម្រែបម្រួលមូលធន
- សេចក្តីព្រាងលក្ខន្តិកៈក្រុមហ៊ុនដែលនឹងបង្កើត
- ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ភាគទុនិក÷ លិខិតឆ្លងដែន ឬអត្តសញ្ញាណបណ្ណថតចម្លង (សម្រាប់ភាគទុនិកជារូបវន្តបុគ្គល) ឬ ឯកសារគតិយុត្តអំពីអាជីវកម្ម និងអាសយដ្ឋានទីស្នាក់ការកណ្តាល (សម្រាប់ភាគទុនិកជានីតិបុគ្គល)

WA

- ឯកសារថតចម្លង បញ្ជាក់អំពីគុណវុឌ្ឍិរបស់បុគ្គល ដែលត្រូវតែងតាំងជាប្រធាននិងសមាជិកក្រុមប្រឹក្សាភិបាល ។ ឯកសារមានជាអាទិ៍÷ លិខិតឆ្លងដែន ឬអត្តសញ្ញាណបណ្ណថតចម្លង ប្រវត្តិរូបសង្ខេបស្តីពីបទពិសោធន៍ការងារនិងការសិក្សាដោយភ្ជាប់សញ្ញាបត្រ ឬវិញ្ញាបនបត្រជំនាញ
- ឯកសារបញ្ជាក់នាមករណ៍បម្រុងទុករបស់ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវលម្អិតខាងលើ ក្រសួងមានសិទ្ធិសម្រេចចេញគោលការណ៍អនុញ្ញាត ឬបដិសេធលើសំណើសុំក្នុងរយៈពេល ៤៥ ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ ដែលមានសំណុំលិខិតគ្រប់គ្រាន់។ លិខិតអនុញ្ញាតជាគោលការណ៍នេះ ចេញជូនសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និងបន្តនីតិវិធីផ្សេងៗទៀតតាមការចាំបាច់ ។

**ប្រការ ៧._**

បន្ទាប់ពីទទួលបានគោលការណ៍អនុញ្ញាត និងបានចុះបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុនត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងបន្ត ដោយភ្ជាប់ឯកសារតម្រូវលម្អិតដូចខាងក្រោម÷

- លិខិតស្នើសុំអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងដែលចុះហត្ថលេខាដោយប្រធាន ឬសមាជិកក្រុមប្រឹក្សាភិបាល
- ពាក្យស្នើសុំអាជ្ញាបណ្ណដែលបានបំពេញ និងចុះហត្ថលេខាដោយប្រធាន ឬសមាជិកក្រុមប្រឹក្សាភិបាល
- លិខិតអនុញ្ញាតជាគោការណ៍ក្នុងការប្រកបអាជីវកម្មធានារ៉ាប់រងបន្តដែលចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លក្ខន្តិកៈនិងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនក្នុងទ្រង់ទ្រាយជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត
- រចនាសម្ព័ន្ធ និងសមាសភាពគណៈគ្រប់គ្រង របស់ក្រុមហ៊ុន
- លិខិតថ្កោលទោសរបស់ភាគទុនិកជារូបវន្តបុគ្គល និង ប្រធាននិងសមាជិកក្រុមប្រឹក្សាភិបាល
- គោលការណ៍ធានារ៉ាប់រងបន្ត របស់ក្រុមហ៊ុន
- គោលការណ៍អភិបាលកិច្ច របស់ក្រុមហ៊ុន
- គោលការណ៍ណែនាំគណនេយ្យរបស់ក្រុមហ៊ុន
- គោលការណ៍ណែនាំស្តីពីកំណត់តម្លៃ និង ហានិភ័យ របស់ក្រុមហ៊ុន
- គោលការណ៍ណែនាំស្តីពីការទប់ស្កាត់នឹងការសំអាតប្រាក់ របស់ក្រុមហ៊ុន
- គោលការណ៍ណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងហានិភ័យផ្សេងទៀត របស់ក្រុមហ៊ុន

- លិខិតបញ្ជាក់ដើមទុនអប្បបរមា ៥ ០០០ ០០០ (ប្រាំលាន)អេសឌីអ័រសម្រាប់ ០១(មួយ) ប្រភេទធានារ៉ាប់រងដូចជា ធានារ៉ាប់រងអាយុជីវិត ឬ ធានារ៉ាប់រងទូទៅ ពីធនាគារពាណិជ្ជដែលធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា
- លិខិតបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្ម ១០% នៃដើមទុនអប្បបរមាសម្រាប់ ០១(មួយ) ប្រភេទធានារ៉ាប់រងដូចជា ធានារ៉ាប់រងអាយុជីវិត ឬ ធានារ៉ាប់រងទូទៅ ក្នុងគណនីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លិខិតបញ្ជាក់ប្រាក់កម្រិតសាធនភាពអប្បបរមា ៥០% នៃដើមទុនអប្បបរមាសម្រាប់ ០១ (មួយ)ប្រភេទធានារ៉ាប់រងដូចជា ធានារ៉ាប់រងអាយុជីវិត ឬ ធានារ៉ាប់រងទូទៅ រក្សាទុកនៅធនាគារពាណិជ្ជក្នុងព្រះរាជាណាចក្រកម្ពុជា
- បណ្ណប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ប៉ាតង់ ថតចម្លង
- កិច្ចសន្យាជួលទីតាំង ឬបណ្ណកម្មសិទ្ធិ ថតចម្លង ដោយមានបញ្ជាក់ដោយសារការី
- លិខិតបញ្ជាក់ទីតាំងប្រកបអាជីវកម្មពីអាជ្ញាធរមូលដ្ឋាន
- ឯកសារថតចម្លង បញ្ជាក់អំពីគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជា អគ្គនាយក និង អ្នកជំនាញគណនាតម្លៃហានិភ័យធានារ៉ាប់រង មានជាអាទិ៍÷ លិខិតឆ្លងដែន ឬអត្តសញ្ញាណបណ្ណថតចម្លង ប្រវត្តិរូបសង្ខេបស្តីពីបទពិសោធន៍ការងារ និងការសិក្សា ដោយភ្ជាប់សញ្ញាបត្រ ឬវិញ្ញាបនបត្រជំនាញ ។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវលម្អិតខាងលើ ក្រសួងមានសិទ្ធិសម្រេចចេញអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងបន្ត ឬបដិសេធលើសំណើសុំអាជ្ញាបណ្ណក្នុងរយៈពេល ៤៥ ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំដែលមានសំណុំលិខិតគ្រប់គ្រាន់។

**ប្រការ ៨.**_

បុគ្គលដែលមានបំណងប្រកបអាជីវកម្មធានារ៉ាប់រងបន្តជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬសាខាក្រុមហ៊ុនបរទេសត្រូវផ្តល់ឯកសារដូចមានចែងក្នុងប្រការ៦ និងប្រការ៧ និងត្រូវបន្ថែមឯកសារដូចខាងក្រោម÷

១. សំណើសុំគោលការណ៍អាជីវកម្មធានារ៉ាប់រងបន្ត

- ព័ត៌មានអំពីប្រវត្តិសង្ខេបនៃសម្ព័ន្ធក្រុមហ៊ុន ឬក្រុមហ៊ុនមេ
- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបស់សម្ព័ន្ធក្រុមហ៊ុន ឬក្រុមហ៊ុនមេសម្រាប់រយៈពេលបីឆ្នាំចុងក្រោយ
- ព័ត៌មានស្តីពីចំណាត់ថ្នាក់របស់សម្ព័ន្ធក្រុមហ៊ុន ឬក្រុមហ៊ុនមេនៅក្នុងប្រទេសដើម និងក្នុងសកលលោកដោយមានការវាយតម្លៃរបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ជាអន្តរជាតិ

hn

- រចនាសម្ព័ន្ធគ្រប់គ្រងរបស់សម្ព័ន្ធក្រុមហ៊ុន ឬក្រុមហ៊ុនមេ។

២. សំណើសុំអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងបន្ត

- លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណប្រកបអាជីវកម្ម របស់សម្ព័ន្ធក្រុមហ៊ុន ឬក្រុមហ៊ុនមេ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើម
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនសម្ព័ន្ធក្រុមហ៊ុន ឬក្រុមហ៊ុនមេ អនុញ្ញាតឱ្យប្រកបអាជីវកម្មធានារ៉ាប់រងបន្តក្នុងព្រះរាជាណាចក្រកម្ពុជា
- លិខិតអនុញ្ញាតរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើម ឱ្យប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ ក្រសួងមានសិទ្ធិសម្រេចចេញអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងបន្ត ឬ បដិសេធលើសំណើសុំអាជ្ញាបណ្ណក្នុងរយៈពេល និងតាមលក្ខខណ្ឌដូចបានកំណត់ក្នុងប្រការ ៦ និង ប្រការ ៧ ។

**ប្រការ ៩._**

អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងបន្តសម្រាប់ក្រុមហ៊ុនបង្កើតថ្មី ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬសាខាក្រុមហ៊ុនបរទេស មានសុពលភាពមិនកំណត់ចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ ដោយក្រុមហ៊ុនត្រូវបង់កម្រៃអាជ្ញាបណ្ណសម្រាប់ឆ្នាំដំបូងចំនួន ៨០០ ០០០ ០០០ (ប្រាំបីរយលាន) រៀល និងកម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំសម្រាប់ឆ្នាំបន្ទាប់ ចំនួន ៥០ ០០០ ០០០ (ហាសិបលាន) រៀល។ អាជ្ញាបណ្ណនេះមិនអាចផ្ទេរ ឬ លក់បានឡើយ។

**ប្រការ ១០._**

ក្រោយពីបានទទួលអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងបន្ត ប្រសិនបើសាមីក្រុមហ៊ុនធានារ៉ាប់រងបន្តមិនបានចាប់ផ្តើមធ្វើប្រតិបត្តិការអាជីវកម្មធានារ៉ាប់រងបន្តនៅក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃទទួលបានអាជ្ញាបណ្ណនោះទេ អាជ្ញាបណ្ណនឹងត្រូវអស់សុពលភាពដោយស្វ័យប្រវត្តិ លើកលែងតែមានការអនុញ្ញាតពីក្រសួង។

**ប្រការ ១១._**

ក្រុមហ៊ុនធានារ៉ាប់រងបន្តទាំងអស់មានសិទ្ធិផ្លាស់ប្តូរ ឬ កែប្រែអាសយដ្ឋាន ឬ សមាសភាពភាគទុនិក ឬ សមាសភាពក្រុមប្រឹក្សាភិបាល ឬ គណៈគ្រប់គ្រង បាន ដោយស្នើសុំការអនុញ្ញាតជាមុនពីក្រសួង។

HL

**ប្រការ ១២._**

ក្រុមហ៊ុនធានារ៉ាប់រងបន្ត មានសិទ្ធិចុះកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តចូលនិងបន្តចេញបាន លុះត្រាតែមានការអនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ ១៣._**

ក្រុមហ៊ុនធានារ៉ាប់រងបន្តត្រូវបង់កម្រៃអាជ្ញាបណ្ណ និងប្រាក់ពិន័យចូលគណនីទោលរតនាគារជាតិ នៅធនាគារជាតិនៃកម្ពុជាតាមដីកាអមរបស់នាយកដ្ឋានធានារ៉ាប់រង និងសោធន។

## ជំពូកទី ៣

## ពិន័យអន្តរការណ៍

**ប្រការ ១៤._**

ក្រុមហ៊ុនធានារ៉ាប់រងបន្តណាដែលអនុវត្តផ្ទុយនឹងប្រការ ១១ នៃប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងនូវចំនួនទឹកប្រាក់ ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៣០ ០០០ ០០០ (សាមសិបលាន) រៀល ។

**ប្រការ ១៥._**

ក្រុមហ៊ុនធានារ៉ាប់រងបន្តណាដែលអនុវត្តផ្ទុយនឹងប្រការ ១២ នៃប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍នូវចំនួនទឹកប្រាក់ ពី ២០ ០០០ ០០០(ម្ភៃលាន) រៀល ទៅ ៤០ ០០០ ០០០(សែសិបលាន) រៀល។

**ប្រការ ១៦._**

ក្រុមហ៊ុនធានារ៉ាប់រងបន្តណា ដែលមានការយឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំ និងប្រាក់ផាកពិន័យតាមកាលកំណត់ក្នុងដីកាអមរបស់នាយកដ្ឋានធានារ៉ាប់រង និងសោធន ត្រូវទទួលរងពិន័យអន្តរការណ៍ពីក្រសួងនូវចំនួនទឹកប្រាក់ ដូចខាងក្រោម÷

- ចំនួន ៤ ០០០ ០០០(បួនលាន)រៀល យឺតចាប់ពី ១(មួយ)ថ្ងៃ ដល់ ៥(ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ
- ចំនួន ១០ ០០០ ០០០ (ដប់លាន)រៀល យឺតលើសពី ៥ថ្ងៃ នៃថ្ងៃធ្វើការ និងអាចទទួលទណ្ឌកម្ម ខាងវិន័យដូចមានចែងក្នុងច្បាប់ស្តីពីការធានារ៉ាប់រង។

**ប្រការ ១៧._**

ក្រុមហ៊ុនធានារ៉ាប់រងបន្តណាដែលមានប្រតិបត្តិការជាមួយអន្តរការីធានារ៉ាប់រងណាមួយដែលគ្មានអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងនូវចំនួនទឹកប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ដល់ ៤០ ០០០ ០០០(សែសិបលាន)រៀល ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**ប្រការ ១៨._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៩._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១៤កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ១៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ